**កំណាព្យ** **សំដី** **បទពាក្យ ៧**

-ចាស់ថាជាតិមនុស្សយកសំដី
ក្មេងថាដើរយកគ្នាវា
ចំណែកឯខ្ញុំបាទសុខគា
វាយបទពណ៌នាពីសំដី ។

-សំដីជាឯកលេខជាទោ
ពាក្យពេចន៍លេចធ្លោទាំងប្រុសស្រី
បានសុខបានទុក្ខព្រោះសំដី
ក្រេវក្រោធលោតវាយព្រោះវាចា ។

-សំដីជាស្ករផ្អែមត្រជាក់
សំដីអាចស្ទាក់ឃាត់ហិង្សា
សំដីពិរោះឆ្ងាញ់ពិសារ
សំដីចចារទន់ទាំងឆ្អឹង ។

-សំដីអោយមនុស្សវង្វេងបាន
សំដីនាំប្រាណអោយនឹងធឹង
សំដីអោយមនុស្សចេះថ្លែងថ្លឹង
សំដីនាំខឹងក្តៅក្រហាយ ។

-សំដីអោយមនុស្សដាច់ពោះស្លាប់
សំដីចាក់កាប់ប្រាប់អន្តរាយ
សំដីអោយមនុស្សបានដុំបាយ
សំដីនាំកាយអោយថ្លៃថ្លា ។

-សំដីនាំជោគនាំរាសី
សំដីនាំយសនាំសក្តា
សំដីអាចប្រើផ្លូវមុសា
សំដីខ្លោចផ្សាទាំងក្មេងចាស់ ។

-សំដីដើមហេតុនៃសង្គ្រាម
សំដីនាំឈាមអោយកកស្ទះ
សំដីនាំគ្រោះចូលក្នុងផ្ទះ
សំដីផ្សារផ្សះជំលោះបាន ។

-សំដីស្មើនឹងទឹកអាស៊ីត
សំដីគ្រោតគ្រាតហៅសាមាន្យ
សំដីនាំមនុស្សអោយសុខសាន្ត
កុំខានជ្រើសរើសសំដីប្រើ ។

-សំដីណាល្អនាំថ្លាថ្លៃ
គួររើសមកច្នៃអោយប្រសើរ
កុំគិតថាខ្លួនឯងគ្រាន់បើ
ស្លាប់រស់ទើតើព្រោះសំដី ។!

ដោយ **ជួន សុខគា**
016 82 84 29.